**សេចក្តីថ្លែងសារព័ត៌មាន**

# កម្ពុជាធ្វើជាម្ចាស់ផ្ទះដោយជោគជ័យនៃសន្និសីទលើកដំបូង កម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ី (ERIP) ដែលមានការចូលរួមពីប្រទេសចំនួន២០

*អង្គការអភិរក្សអន្តរជាតិកម្ពុជា រួមជាមួយកម្មវិធីសហប្រជាជាតិនៅកម្ពុជា និងក្រសួងបរិស្ថាន បានរៀបចំសន្និសីទប្រចាំឆ្នាំលើកទី១ កម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ីនៅក្នុងខេត្តសៀមរាប ដោយមានអ្នកចូលរួមប្រមាណ ៨០នាក់មកពី ២០ប្រទេស ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការស្តារប្រព័ន្ធអេកូឡូស៊ីជុំវិញពិភពលោក។*

**ខេត្តសៀមរាប ប្រទេសកម្ពុជា ថ្ងៃទី១ ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៥៖** ដោយសង្កេតឃើញថា មួយភាគប្រាំនៃផ្ទៃដីរបស់ភពផែនដីកំពុងប្រឈមនឹងការសឹករិចរឹល ការគំរាមកំហែងដល់សន្តិសុខស្បៀង ការផ្គត់ផ្គង់ទឹក ជីវៈចម្រុះ និងស្ថិរភាពអាកាសធាតុ ប្រទេសកម្ពុជាបានរៀបចំសន្និសីទប្រចាំឆ្នាំលើកទី១ នៃកម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ី ក្នុងសប្តាហ៍នេះ ដែលជាជំហានដ៏សំខាន់មួយក្នុងការបង្កើនដំណោះស្រាយប្រយុទ្ធប្រឆាំងនឹងវិបត្តិដែលបានរៀបរាប់ខាងលើនេះ។

សន្និសីទនេះសហការរៀបចំដោយអង្គការអភិរក្សអន្តរជាតិ(អង្គការ CI) ក្នុងភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា(UNDP) និងក្រសួងបរិស្ថាន គាំទ្រដោយមូលនិធិមូលនិធិបរិស្ថានសកល (GEF) មានរយៈពេលបួនថ្ងៃ និងមានអ្នកចូលរួមប្រមាណ ៨០នាក់ មកពី ២០ប្រទេសក្នុងតំបន់អាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន។ **លោកជំទាវ ម៉ុម ថានី** រដ្ឋលេខាធិការក្រសួងបរិស្ថាន បានចូលរួមជាគណៈអធិបតីក្នុងពិធីបើកសន្និសីទនេះ ដោយបានថ្លែងសុន្ទរកថាបើក ដោយលើកឡើងពីភាពជាលេចធ្លោនៃកម្ពុជា ក្នុងការជំរុញគោលដៅស្តារឡើងវិញនៃប្រព័ន្ធអេកូឡូស៊ីជាសកល។

**លោកជំទាវ** មានប្រសាសន៍ថា៖ *«ការអនុវត្តកម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ី (ERIP)នៅកម្ពុជា គឺជាយន្តការសំខាន់មួយក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលស្របទៅនឹងផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (NDC 3.0) ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជា ២០២៣-២០៣៣ និងយុទ្ធសាស្ត្រចក្រវិស័យបរិស្ថានជាដើម។ ការស្តារប្រព័ន្ធអេកូឡូស៊ី គឺជាចំណុចស្នូលនៃការសម្រេចបានលទ្ធផលសំខាន់ៗរបស់កម្ពុជា ជាពិសេសតាមរយៈមុខងារស្រូបកាបូនដោយព្រៃឈើ និងការប្រើប្រាស់ដីធ្លីដោយនិរន្តរភាពជាដើម។»* លោកជំទាវបន្តផងថា៖ *«ការណ៍ដែលភ្ជាប់បណ្តាញអន្តរជាតិនៃកម្មវិធី ERIP ជាមួយនឹងយុទ្ធសាស្ត្រជាតិ អាចជួយឱ្យយើងជំរុញសកម្មភាពកាន់តែប្រសើរក្នុងការការពារ និងអភិរក្សជីវៈចម្រុះ ពង្រឹងភាពធន់នឹងអាកាសធាតុ និងផ្តល់អត្ថប្រយោជន៍យូរអង្វែងសម្រាប់មនុស្សជាតិគ្រប់ជំនាន់។»*

**ការជំរុញជាសកលដើម្បីស្តារផ្ទៃដីប្រមាណ ១,៨ លានហិកតា៖** នៅទូទាំងពិភពលោក កម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ី កំណត់គោលដៅលើការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗប្រមាណ ១,៨លានហិកតា និងកែលម្អការគ្រប់គ្រងផ្ទៃដីប្រមាណ ៧០០ពាន់ហិកតា ផ្សេងទៀតនៅតាមតំបន់ការពារជីគោក។ ជារួម សកម្មភាពទាំងនេះត្រូវបានគេរំពឹងថានឹងអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ១៤៥លានតោន និងផ្តល់អត្ថប្រយោជន៍ដល់មនុស្សជាង ៣លាននាក់ ដែលកំពុងពឹងអាស្រ័យលើប្រព័ន្ធអេកូឡូស៊ីដែលមានសុខភាពល្អសម្រាប់ការផ្គត់ផ្គង់អាហារ ទឹក និងជីវភាពរស់នៅ។

**ការណ៍នេះទាមទារឱ្យមានសកម្មភាពជាបន្ទាន់៖** នៅទូទាំងពិភពលោក ផ្ទៃដីប្រមាណ ២០លានគីឡូម៉ែត្រការ៉េ ដែលមានទំហំធំជាងទ្វីបអាមេរិកខាងត្បូងទៅទៀត កំពុងតែប្រឈមមុខនឹងការសឹករិចរិល ការបាត់បង់ជីវៈចម្រុះ និងភាពធន់នឹងអាកាសធាតុ។ ដូច្នេះ តាមរយៈការស្តារប្រព័ន្ធអេកូឡូស៊ី ប្រទេសនានាអាច៖

- ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុតាមរយៈការស្រូបយកកាបូន និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

- ការពារជីវៈចម្រុះដោយការអភិរក្សប្រភេទសត្វជិតផុតពូជ និងទីជម្រករបស់ពួកវា
- ពង្រឹងសន្តិសុខទឹកតាមរយៈការស្តារគុណភាព និងលទ្ធភាពប្រើប្រាស់ទឹក
- លើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុកតាមរយៈការបង្កើតការងារ និងគាំទ្រដល់ជីវភាពរស់នៅប្រកបដោយនិរន្តរភាព។

**ភាពជាអ្នកដឹកនាំរបស់ប្រទេសកម្ពុជាក្នុងការស្តារឡើងវិញ៖** ប្រទេសកម្ពុជាបានបង្ហាញគម្រោងសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ីរបស់ខ្លួនក្នុងអំឡុងពេលសន្និសីទ ដែលនឹងអនុវត្តដោយក្រសួងបរិស្ថាន និង កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិកម្ពុជា (UNDP Cambodia) ។ នៅកម្ពុជា កម្មវិធីនេះគ្របដណ្តប់លើផ្ទៃដីប្រមាណ ២៥៥.០០០ ហិកតា ត្រូវបានអ្នកជំនាញរំពឹងថាអាចនឹងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៥១លានតោន ផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់មនុស្សប្រមាណ ៣២ពាន់នាក់។ សកម្មភាពស្តារឡើងវិញរួមមាន៖ កសិរុក្ខកម្មដែលដឹកនាំដោយសហគមន៍ ការអភិវឌ្ឍច្រករបៀងជីវៈចម្រុះ និងការប្រើប្រាស់គោលការណ៍ទូទាត់សម្រាប់សេវាអេកូឡូស៊ី (PES) ដើម្បីគាំទ្រដល់និរន្តរភាពរយៈពេលវែង។

គណៈប្រតិភូនៃសន្និសីទក៏បានទៅទស្សនាទីតាំងស្តារឡើងវិញនៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»ដែលសហគមន៍បាននិងកំពុងធ្វើការរួមគ្នាជាមួយរាជរដ្ឋាភិបាល ដើម្បីស្តារឡើងវិញនូវតំបន់ទេសភាពដែលសឹករិចរឹល ព្រមទាំងការពារសម្បត្តិបេតិក ភណ្ឌវប្បធម៌ដែរ។

**ការកសាងសន្ទុះសម្រាប់ការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញជាសកល៖** សន្និសីទ ERIP នៅខេត្តសៀមរាបនេះ គឺជាលើកទីដំបូងហើយដែលតំណាងមកពីប្រទេសទាំង២០ បានជួបជុំគ្នានៅទីកន្លែងតែមួយ បង្កើតវេទិកាសកលសម្រាប់កិច្ចសហការ ការផ្លាស់ប្តូរ និងការដោះស្រាយបញ្ហារួមគ្នា។ គណៈប្រតិភូរួមមានតំណាងរាជរដ្ឋាភិបាល អ្នកដឹកនាំសង្គមស៊ីវិល អ្នកវិទ្យាសាស្ត្រ និងដៃគូអន្តរជាតិទាំងអស់បានប្តេជ្ញាចិត្តរួមគ្នាក្នុងការបង្កើនការស្តារឡើងវិញក្នុងល្បឿនមួយដែលសមស្របនឹងភាពបន្ទាន់នៃវិបត្តិនេះ។

បេសកកម្មរបស់ ERIP គឺដើម្បីស្តារប្រព័ន្ធអេកូឡូស៊ីដែលសឹករិករឹល ដើម្បីកសាងអនាគតដ៏រឹងមាំសម្រាប់មនុស្ស និងភពផែនដី។ ដោយអនុលោមតាមទស្សនវិស័យរបស់អង្គការសហប្រជាជាតិស្តីពីការស្តារប្រព័ន្ធអេកូឡូស៊ី កម្មវិធីនេះគាំទ្រការប្តេជ្ញាចិត្តនៃការស្តារឡើងវិញជាសកលតាមរយៈគោលនយោបាយ ហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ កម្មវិធីរួមបញ្ចូលការស្តារប្រព័ន្ធអេកូគឺជាគំនិតផ្តួចផ្តើមរយៈពេល៦ឆ្នាំ ក្រោមទំហំទឹកប្រាក់ប្រមាណ ២០០ លានដុល្លារអាមេរិក ដែលផ្តល់ដោយ Global Environment Facility និងដឹកនាំដោអង្គការCI។ កម្មវិធីនេះមានគោលបំណងស្តារប្រព័ន្ធអេកូឡូស៊ីចំនួន ១,៨ លានហិចតាក្នុងប្រទេសចំនួន២០ នៅតំបន់អាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន។ ព័ត៌មានបន្ថែមអំពីកម្មវិធី សូមចូលទៅកាន់តំណនេះ erip.org

កម្មវិធីសមាហរណកម្មការស្តារប្រព័ន្ធអេកូឡូស៊ី (ERIP) ទទួលថវិកាពីមូលនិធិបរិស្ថានសកល(Global Environment Facility) និងដឹកនាំសម្របសម្រួលអនុវត្តការងារដោយអង្គការអភិរក្សអន្តរជាតិ (អង្គការ CI) ក្នុងភាពជាដៃគូសំខាន់ៗ ដូចជា អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) សហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) ធនាគារពិភពលោក មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម(IFAD) និងអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP)។